# កំហុសជាផ្នែកមួយនៃចំណេះដឹង

## DU POINT DE VUE DE L’APPRENTISSAGE, L’ERREUR EST UNE COMPOSANTE DE LA CONNAISSANCE

Dans une classe de langue, les apprenants ont peur de commettre des erreurs : des causes pour lesquelles certains élèves préfèrent se taire, surtout les élèves débutants. Or dans le processus de l’apprentissage, la sanction des erreurs chez les élèves ne se fait pas par l’enseignant. En revanche, le travail de l’enseignant est de prendre en compte les erreurs commises par les apprenants, trouver les moyens pour que les derniers les évitent pour la prochaine fois et de les encourager à parler. One peut dire que l’erreur est une bonne chose dans le processus de l’apprentissage.



http://ritrisk.files.wordpress.com

តាមទស្សនៈនៃការអប់រំ កំហុសឆ្គង Les erreurs គឺជាធាតុផ្សំនៃការបង្កើតចំណេះដឹង

កំហុសឆ្គង Les erreurs ជាពាក្យដែលយើងគ្រប់គ្នាមិនចូលចិត្តទទួលយកទេ ប៉ុន្តែនៅក្នុងការប្រត្តិបត្តប្រចាំថៃវាគឺជាស្រមោលអន្ទោលតាមប្រាណ។ យ៉ាងណាមិញ នៅក្នុងការសិក្សាភាសាបរទេស កំហុសឆ្គង Les erreurs នេះតែងតែកើតឡើងជារឿយៗចំពោះអ្នកសិក្សាទូទៅ ជាពិសេសនៅក្នុងសមត្ថភាពនិយាយ Expression orale។

ជាទូទៅ នៅពេលចាប់ផ្ដើមរៀននិយាយភាសាបរទេសមួយ យើងតែងតែធ្វើការប្រុងប្រយ័ត្នទាំងនៅក្នុងការនិយាយ និងការសរសេរ ព្រោះមិនចង់ឱ្យកំហុសនេះកើតមានឡើងឡើយ។ ទន្ទឹមនឹងនោះ យើងតែងតែមានអារម្មណ៍ព្រួយបារម្ភណាស់ក្នុងការប្រាស្រ័យទាក់ទង ព្រោះយើងខ្លាចក្រែងនិយាយខុស និយាយមិនត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ឬក្រែងនិយាយទៅគេស្ដាប់មិនយល់។ ប្រការទាំងនេះហើយដែលធ្វើឱ្យយើងមិនចង់និយាយមិនហ៊ាននិយាយ ឬនៅស្ងៀមតែម្ដង។

នៅពេលចាប់ផ្ដើមរៀនភាសាបរទេសមួយ តើលោកអ្នកដែលបានគិតថាធ្លាប់និយាយខុសឬទេ ?

តើលោកអ្នកបានធ្វើខុសលើចំណុចដដែលនោះទៀតទេ ? តើកត្តាអ្វីដែលធ្វើឱ្យលោកអ្នកនិយាយបានត្រឹមត្រូវនោះ ?

យើងខ្ញុំសូមមិនឆ្លើយដោយត្រង់ទៅនឹងសំណួរទាំងនោះទេ ប៉ុន្តែសូមលើកយកករណីនៃការនិយាយភាសារបស់កុមារអាយុចន្លោះពីរឆ្នាំ-បីឆ្នាំមកធ្វើការឆ្លុះបញ្ចាំងទុកជាបទពិសោធន៍។ កុមារនៅក្នុងអាយុនេះ មិនទាន់ចេះនិយាយ ឬនិយាយមិនទាន់ត្រឹមត្រូវទេ ហើយភាសារបស់ម្ដាយឪពុក និងអ្នកដែលនៅជុំវិញខ្លួនរបស់គេ ត្រូវបានចាត់ទុកជាភាសាមួយដ៏ថ្មីស្រឡាង។ កុមារចាប់ផ្ដើមរៀននិយាយភាសារបស់គេតាមរយៈការស្ដាប់ និងការសង្កេត ដោយធ្វើត្រាប់តាមសំឡេងដែលគេស្ដាប់ឮ និងសកម្មភាពដែលគេមើលឃើញ។ តាមការសង្កេត កុមារភាគច្រើនចាប់ផ្ដើមឮសំឡេងមួយ ពាក្យមួយ ហើយគេក៏ធ្វើត្រាប់ដោយបន្លឺតាមសំឡេង និងពាក្យទាំងនោះ។ ពេលដែលគេចេះបន្លឺសំឡេងនេះហើយ កុមារមិននៅស្ងៀមទេ គេបន្តបង្កើតសំឡេងផ្សេងទៀតទាំងត្រូវទាំងខុសរហូតបង្កើតបានជាពាក្យ បង្កើតបានជាឃ្លា និងជាភាសាសម្រាប់ទាក់ទងជាមួយម្ដាយឪពុក និងអ្នកដែលនៅជុំវិញខ្លួនរបស់គេ។

តាមព្រឹត្តិការណ៍នេះ យើងសួរថាតើកុមារបានរៀនក្បួនវេយ្យាករណ៍ពីគ្រូណាម្នាក់ឬទេ ? ក្នុងការនិយាយនោះ តើកុមារនិយាយត្រូវទាំងអស់ឬទេ ? នៅក្នុងការនិយាយនេះ កុមារពិតជានិយាយមិនត្រូវទាំងអស់ទេ ប៉ុន្តែយើងសង្កេតឃើញថាកុមារពុំមានការភ័យខ្លាចក្នុងការនិយាយខុសឡើយ។ ហើយកំហុសទាំងអស់នេះហើយដែលជួយឱ្យកុមារនិយាយបានត្រឹមត្រូវ។

នៅក្នុងការរៀនភាសាបរទេសមួយ ការសិក្សារបស់សិស្សានុសិស្សប្រព្រឹត្តទៅមិនខុសអ្វីពីសកម្មភាពរបស់កុមារខាងលើនេះឡើយ។ គ្រូជាអ្នកផ្ដើមបង្កើតសញ្ញាណជាមូលដ្ឋានគ្រឹះសម្រាប់ប្រាស្រ័យទាក់ទងជាមួយសិស្ស ដោយប្រើប្រាស់នូវភាសាកម្រិតសាមញ្ញដែលងាយយល់។ ផ្ដើមចេញពីចំណុចនេះ សិស្សានុសិស្សធ្វើការសង្កេតរៀនធ្វើឃ្លាប្រយោគតាមគំរូដែលមានស្រាប់ បន្ទាប់មកធ្វើការសន្ទនា ប្រាស្រ័យទាក់ទងជាមួយគ្រូ និងជាមួយមិត្តភក្តិនៅក្នុងថ្នាក់ (អន្តរកម្មរវាងគ្រូ-សិស្ស និងរវាងសិស្ស-សិស្ស)។ នៅក្នុងដំណាក់កាលនេះ កំហុសឆ្គងទាំងឡាយប្រាកដជានឹងកើតមានឡើង ដោយរួមមានទាំងកំហុសនៃការបន្លឺសំឡេង la phonétique កំហុសវេយ្យាករណ៍ la grammaire និងកំហុសផ្សេងៗទៀត។

ឆ្លៀតឱកាសនៅពេលដែលឃើញសិស្សធ្វើកំហុសឆ្គងនេះ លោកគ្រូអ្នកគ្រូត្រូវគិតថាគឺជាជំហានវិជ្ជមានមួយដែលយើងត្រូវយកចិត្តទុកដាក់ក្នុងការកែតម្រូវកំហុសរបស់សិស្សទាំងនោះ ដោយប្រើប្រាស់វិធីសាស្ត្រដ៏ឈ្លាសវៃនិងដោយមានការលើកទឹកចិត្តផង។ ជាពិសេសយើងអាចផ្តល់ឱកាសឱ្យសិស្សកែតម្រូវដោយខ្លួនឯង auto correction ឬក្រុមសិស្សរកឃើញកំហុសហើយកែតម្រូវមិត្តភក្តិរបស់គេ។

តាមគរុកោសល្យទំនើបនៃការរៀន-បង្រៀនភាសាបរទេស កំហុសឆ្គងក្នុងការនិយាយរបស់សិស្ស ត្រូវបានលើកទឹកចិត្តឱ្យកែតម្រូវដោយមិនត្រូវដាក់ទណ្ឌកម្មឡើយ ព្រោះស្តែងចេញពីកំហុសឆ្គងនេះ អ្នកសិក្សាអាចរកឃើញដោយខ្លួនឯងនូវចម្លើយដែលត្រឹមត្រូវ ហើយដែលគេអាចយកទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។



www3.sympatico.ca

ដូច្នេះការរៀនភាសាបរទេសរបស់មនុស្សទូទៅមិនខុសអ្វីពីស្ថានភាពរៀនភាសារបស់កុមារឡើយ។ សិស្សគឺជាអ្នកផលិតចំណេះដឹង និងសមត្ថភាពផ្ទាល់របស់ពួកគេ។ ចូរយើងសិក្សាឡើងវិញពីកំហុសរបស់យើង នោះយើងនឹងចៀសវាងបាននូវកំហុសឆ្គងសម្រាប់ពេលក្រោយ ហើយឈានទៅរកការរីកចំរើនក្នុងការនិយាយភាសា។ ការដែលយើងធ្វើកំហុសនៅពេលនិយាយភាសាបរទេស ជួយយើងឱ្យនិយាយកាន់តែប្រសើរឡើង។ ប្រសិនបើយើងតាំងចិត្តថានិយាយមិនឱ្យខុស នោះជាការប្រសើរណាស់ ប៉ុន្តែប្រហែលជាយើងត្រូវប្រើប្រាស់តែពាក្យងាយៗ ដដែលៗតែប៉ុណ្ណោះ។ ចូរយើងក្លាហានក្នុងការប្រើប្រាស់នូវពាក្យថ្មី វេយ្យាករណ៍ថ្មី ។ ជួនកាលយើង នឹងប្រថុយក្នុងការនិយាយខុសដំបូងមុននឹងឈានទៅដល់ការប្រើប្រាស់បានត្រឹមត្រូវ។ កំហុសឆ្គង Les erreurs នៅក្នុងសមត្ថភាពនិយាយ ឬសមត្ថភាពសរសេរ ជាចំណែកដ៏សំខាន់ដែលជំរុញឱ្យយើងនិយាយភាសា បានត្រឹមត្រូវ និងកាន់តែចម្រើនឡើង។

អ៊ុក ឧត្តរៈ អធិការភាសាបារាំងនៅវិទ្យាស្ថានជាតិអប់រំ

## គំនិតល្អៗទាំង១០ សម្រាប់រៀនភាសាបារាំង

### 10 RAISONS POUR APPRENDRE LE FRANÇAIS

១. ភាសាមួយដែលគេនិយាយនៅទូទាំងពិភពលោក

មនុស្សជាង ២០០លាននាក់ និយាយភាសាបារាំង នៅលើទ្វីបទាំង៥។ ប្រទេសនិយាយភាសាបារាំងរួមមាន ៦៨ រដ្ឋ និងរដ្ឋាភិបាល។ ភាសាបារាំងគឺជាភាសាបរទេសដែលត្រូវបានគេសិក្សាយ៉ាងទូលំទូលាយបន្ទាប់ពីភាសាអង់គ្លេស និងជាភាសាទី៩ដែលគេនិយាយច្រើនជាងគេនៅលើពិភពលោក។

វាក៏ជាភាសាតែមួយគត់ ជាមួយនឹងភាសាអង់គ្លេស ដែលគេអាចរៀននៅក្នុងប្រទេសនានានៅក្នុងពិភពលោក។ ប្រទេសបារាំងបានរៀបចំបណ្តាញគ្រឹះស្ថានវប្បធម៌ធំជាងគេនៅបរទេស ដែលមានការបង្រៀនភាសាបារាំងដល់មនុស្សជាង ៧៥០ ០០០ នាក់។

២. ភាសាដើម្បីស្វែងរកការងារ

និយាយភាសាបារាំង និងភាសាអង់គ្លេស គឺជាសន្លឹកបៀពិសេសដើម្បីបង្កើនសំណាងក្នុងការស្វែងរកការងារនៅលើទីផ្សារអន្តរជាតិ។ ចំណេះដឹងភាសាបារាំង បើកច្រកសហគ្រាសបារាំងនៅក្នុងប្រទេសបារាំងក៏ដូចជានៅបរទេសក្នុងប្រទេសនិយាយភាសាបារាំងទាំងឡាយ មានដូចជាកាណាដា ស្វីស បែលស៊ិច និង ទ្វីបអាហ្វ្រិក ។ ប្រទេសបារាំងដែលជាមហាអំណាចពាណិជ្ជកម្មទី៥ ជាប្រទេសទី៣សម្រាប់ទទួលវិនិយោគបរទេស ហើយក៏ជាដៃគូសេដ្ឋកិច្ចទីមួយ។

៣. ភាសានៃវប្បធម៌

ភាសាបារាំង គឺជាភាសាអន្តរជាតិសម្រាប់ម្ហូបអាហារ ម៉ូត ល្ខោន សិល្បៈ របាំ និងស្ថាបត្យកម្ម។ ចេះភាសាបារាំង គឺមានលទ្ធភាពស្វែងច្រកចូលដល់ប្រភពអត្ថបទអក្សរសិល្ប៍បារាំង និងអក្សរសិល្ប៍នៃប្រទេសនិយាយភាសាបារាំង ហើយក៏ជាការឈានទៅដល់ការយល់ដឹងពីភាពយន្តនិងចម្រៀងផងដែរ។ ភាសាបារាំង គឺជាភាសារបស់វិចទ័រ អ៊ុយហ្គោ ម៉ូលីយ៉ែ ឡេអូប៉ូល សង់ដា សង់ហ្គោ អេឌីតព្យ៉ាស ហ្សង់ប៉ូលសាត្រ អាឡាំងដឺឡុង ឬ ហ្សីណាឌីន ហ្សីដាន់។